ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 05 / 2012
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E172/24

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ៖ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២

**ជូនចំពោះ៖** ភាគីនៃសំណុំរឿង ០០២; អង្គភាពគាំពារសាក្សី និងអ្នកជំនាញ

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រមទាំងអស់ និងមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ព័ត៌មានបច្ចុប្បន្នភាពទាក់ទិននឹងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្ម អ្នកជំនាញដែលភាគីបានស្នើសុំ ២

បន្ថែមពីលើអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ ទាក់ទិននឹងការកំណត់កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មរបស់អ្នកជំនាញមួយចំនួនដែលភាគីបានស្នើសុំ (ឯកសារ E172/17) អង្គជំនុំជម្រះសូមផ្តល់ព័ត៌មានបច្ចុប្បន្នភាពជូនភាគី ពាក់ព័ន្ធនឹងកាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មរបស់អ្នកជំនាញដែលភាគីបានស្នើសុំ រួមទាំងពេលវេលាសម្រាប់អង្គជំនុំជម្រះ និងភាគីសួរសំណួរដល់ពួកគាត់ ដូចខាងក្រោម៖

- អ្នកជំនាញឈ្មោះ David Chandler៖ ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ (ចំនួន ៥ ថ្ងៃ)។
- អ្នកជំនាញឈ្មោះ Philip Short៖ ពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (ចំនួន ៦ ថ្ងៃ ដោយរួមទាំងថ្ងៃ សុក្រ ទី ០៥ ខែ តុលា ឆ្នាំ ២០១២)។

- អ្នកជំនាញឈ្មោះ Elizabeth Becker៖ នៅថ្ងៃទី ១៧, ១៨, ១៩, ២៣ និង ២៤ ខែ តុលា ឆ្នាំ ២០១២ (ចំនួន ៥ ថ្ងៃ)។ ដោយសារអ្នកជំនាញដែលភាគីបានស្នើសុំរូបនេះអវត្តមាននៅថ្ងៃ ច័ន្ទ ទី ២២ ខែ តុលា អង្គជំនុំជម្រះនឹងមិនធ្វើសវនាការនៅថ្ងៃនោះទេ ប៉ុន្តែអង្គជំនុំជម្រះនឹងធ្វើសវនាការនៅថ្ងៃ សុក្រ ទី ១៩ ខែ តុលា ឆ្នាំ ២០១២ ជំនួសវិញ។
- អ្នកជំនាញឈ្មោះ Henri Locard៖ ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ (ចំនួន ៣ ថ្ងៃ)។

ថ្វីដ្បិតអ្នកជំនាញដែលភាគីស្នើសុំស្តាប់សក្ខីកម្ម បានទទួលសេចក្តីសង្ខេបនៃសក្ខីកម្មពីអង្គជំនុំជម្រះ ដែលភាគីបានផ្តល់ក៏ដោយ ក៏អ្នកជំនាញទាំងនេះបានស្នើសុំព័ត៌មានបន្ថែមដើម្បីសម្របសម្រួលឱ្យមានការត្រៀមរៀបចំឱ្យកាន់តែមានប្រសិទ្ធភាពនៅមុនពេលនៃការផ្តល់សក្ខីកម្មរបស់ពួកគាត់។ អង្គជំនុំជម្រះស្នើឱ្យភាគីដែលបានស្នើសុំសក្ខីកម្មរបស់អ្នកជំនាញដែលខ្លួនបានស្នើខាងលើ ផ្តល់ឱ្យអ្នកជំនាញទាំងនោះនូវសេចក្តីបញ្ជាក់លម្អិតបន្ថែមអំពីវិសាលភាពនៃការសួរសំណួរដែលខ្លួនមានបំណងធ្វើ តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឱ្យបានត្រឹមថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២ សម្រាប់អ្នកជំនាញខាងលើ ហើយក៏ដូចជា ទៅថ្ងៃមុខ សម្រាប់អ្នកជំនាញផ្សេងទៀតដែលភាគីស្នើសុំ និងដែលអង្គជំនុំជម្រះអាចសម្រេចស្តាប់សក្ខីកម្ម។

អង្គជំនុំជម្រះសាលាដំបូងសូមធ្វើការជូនដំណឹងជាមុនដល់ភាគីថា អង្គជំនុំជម្រះនឹងសួរដេញដោលអ្នកជំនាញខាងលើនេះលើរាល់បញ្ហាទាំងឡាយ ដែលពួកគាត់អាចមានលទ្ធភាពឆ្លើយ ក្នុងវិសាលភាពនៃដីកាដំណោះស្រាយសំណុំរឿង ០០២ (*សូមមើល* ឯកសារ E188 កថាខណ្ឌ ៦ (ទាក់ទិននឹងអ្នកជំនាញឈ្មោះ David Chandler និងអ្នកជំនាញឈ្មោះ Henri Locard ) និងឯកសារ E141 ដោយកត់សម្គាល់ថា "សេចក្តីណែនាំអំពីតម្រូវការទៅលើវិសាលភាពនៃសក្ខីកម្មរបស់អ្នកជំនាញទាក់ទិននឹងសំណុំរឿង ០០២/០១ នឹងត្រូវផ្តល់ជូនដោយអង្គជំនុំជម្រះ ក្នុងករណីយល់ឃើញថាចាំបាច់")។